ខេមបូច
CambojA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
Cambodian Journalists Alliance Association



របាយការណ៍ឃ្លាំមើលប្រចាំត្រីមាសស្តីពី
ស្ថានភាពសារព័ត៌មាននៅកម្ពុជា

ខែមេសា - មិថុនា ឆ្នាំ២០២៦ | លេខចេញផ្សាយ ២០

សេចក្តីថ្លែងអំណរគុណ

វិធីសាស្ត្រតាមដានដែលបានប្រើប្រាស់ក្នុងរបាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយបានសហការជាមួយអ្នកស្រី Dara Torsner ជាសាស្ត្រាចារ្យ និងជាអ្នកស្រាវជ្រាវអំពីសុវត្ថិភាពអ្នកសារព័ត៌មានមកពីចក្រភពអង់គ្លេស។ យើងសូមថ្លែងអំណរគុណជាខ្លាំងចំពោះអ្នកស្រីសាស្ត្រាចារ្យដែលបានផ្តល់នូវការប្រឹក្សាដ៏មានតម្លៃក្នុងការបង្កើតទាំងវិធីសាស្ត្រនិងការរៀបចំរបាយការណ៍នេះ។

មាតិកា

១. សេចក្តីសង្ខេប ៤

២. សេចក្តីផ្តើម ៦

៣. វិធីសាស្ត្រឃ្លាំមើលផ្អែកលើសិទ្ធិមនុស្ស ៨

៤. ការរកឃើញសំខាន់ៗ ១២

៥. បច្ចុប្បន្នភាពករណីដែលបានចងក្រងពីមុន ១៨

៦. សេចក្តីសន្និដ្ឋាន ២០

៧. ឧបសម្ព័ន្ធ ២២

១. សេចក្តីសង្ខេប

ខេមបូចា បន្តចងក្រងករណីរំលោភបំពានលើអ្នកសារព័ត៌មាន និងស្ថានភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៦ (ខែមេសា ដល់ ខែមិថុនា) របាយការណ៍ឃ្លាំមើលរបស់ខេមបូចា បានបង្ហាញពីបញ្ហាប្រឈមដែលនៅតែបន្តកើតមានចំពោះសេរីភាពសារព័ត៌មាន និងសិទ្ធិមនុស្សជាមូលដ្ឋាននៅក្នុងប្រទេស។ ក្នុងអំឡុងពេលនេះ ខេមបូចា បានកត់ត្រាការរំលោភបំពានសិទ្ធិលើ អ្នកសារព័ត៌មានចំនួន ១២ករណី ដែល់ពាក់ព័ន្ធដោយផ្ទាល់នឹងសកម្មភាពសារព័ត៌មាន ។ ការរំលោភបំពានដែលត្រូវបានកត់ត្រាទាំងនេះ រួមមាន ការបំភិតបំភ័យ និងវិធានការតាមផ្លូវច្បាប់ ដែលមានរហូត ដល់ ៣៣% នៃការរំលោភបំពានសិទ្ធិសរុប ការរំលោភបំពានសិទ្ធិលើសុវត្ថិភាពផ្នែករាងកាយ (១៧%) ការរំលោភសិទ្ធិលើសុវត្ថិភាពផ្នែកផ្លូវចិត្ត (១៧%) និងការរំលោភបំពាន ផ្សេងៗទៀតលើសិទ្ធិសេរីភាព បញ្ចេញមតិ (៣៣%) ។ ទិន្នន័យនេះបង្ហាញថា ការគំរាមកំហែងដោយប្រើវិធានការច្បាប់ និងចំណាត់ការផ្លូវច្បាប់ ដើម្បីរឹតត្បិត ការរាយការណ៍ព័ត៌មានដោយឯករាជ្យនៅតែបន្តកើតមាន ។

អ្នកសារព័ត៌មានដែលរងផលប៉ះពាល់រួមមាន អ្នករាយការណ៍ព័ត៌មាន អ្នកថតរូប ចាងហ្វាងសារព័ត៌មាន ការីនិពន្ធពលរដ្ឋអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ។ អ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ភាគច្រើន ដែលរងផលប៉ះពាល់បានរាយការណ៍ថា ពួកគេត្រូវបានតម្រូវឱ្យទទួលស្គាល់កំហុសដែលត្រូវបានចោទប្រកាន់ ការតម្រូវឱ្យសរសេរលិខិតសុំទោស និងយល់ព្រមលុបមាតិកា ឬរូបថតដែលបានផ្សព្វផ្សាយ និងថតក្នុងអំឡុងពេលយកព័ត៌មាន ។ អ្នកសារព័ត៌មានផ្សេងទៀត ត្រូវបានស្ថិតក្រោម តាមឃ្លាំមើល ឬត្រូវបានរឹតត្បិត លើសេរីភាពបញ្ចេញមតិ ខណៈពេលកំពុងរាយការណ៍ពីព្រឹត្តិការណ៍ នៅទីសាធារណៈ ។

តួអង្គរដ្ឋ ជាពិសេសអាជ្ញាធរថ្នាក់មូលដ្ឋាន នៅតែជាតួអង្គដែលត្រូវបានចោទថាជាអ្នកទទួលខុសត្រូវចម្បងចំពោះ ការរំលោភបំពានដែលបានចងក្រងក្នុងត្រីមាសនេះ ខណៈដែលការរំលោភបំពានទាំងនេះជាញឹកញាប់មិនទទួលបានការផ្តន្ទាទោសឡើយ ។ ការរំលោភបំពានទាំងនេះ បានបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើអ្នកសារព័ត៌មានម្នាក់ៗ រួមមាន ការរឹតត្បិតសេរីភាព ការបង្ករឱ្យមានភាពតានតឹងផ្លូវចិត្ត ការបង្ខំឱ្យទទួលស្គាល់កំហុស ការចុះហត្ថលេខាលើលិខិតសុំទោស និងការដាក់កំហិតលើខ្លួនឯងជាដើម ។

ការរកឃើញក្នុងត្រីមាសនេះ បង្ហាញពីលំនាំស្រដៀងគ្នានឹងអ្វីដែលត្រូវបានសង្កេតឃើញក្នុងត្រីមាសទី១ ឆ្នាំ២០២៦ ដោយវិធានការផ្លូវច្បាប់ត្រូវបានប្រើជាញឹកញាប់ ដើម្បីបំភិតបំភ័យ ឬបំបិទសំឡេងអ្នកសារព័ត៌មាន ដែលរាយការណ៍ពីបញ្ហារសើប ឬប្រធានបទពាក់ព័ន្ធនឹងការធបោកតាមអនឡាញ ឬប៉ះពាល់បុគ្គលដែលមានឥទ្ធិពលផ្នែកសេដ្ឋកិច្ច ។

ប្រធានបទនៃសេចក្តីរាយការណ៍ដែលនាំឱ្យមានការរំលោភបំពានសិទ្ធិច្រើនជាងគេក្នុងត្រីមាសនេះ គឺការរាយការណ៍ពីឧក្រិដ្ឋកម្មជាពិសេសការធបោកតាមអនឡាញ ដែលអ្នកសារព័ត៌មានត្រូវបានចាប់ខ្លួន និងចោទប្រកាន់ដោយអាជ្ញាធរពីបទញុះញង់ ឬផ្សព្វផ្សាយ «ព័ត៌មានក្លែងក្លាយ» ដែលត្រូវបានចាត់ទុកថាប៉ះពាល់ដល់កេរ្តឹ៍ឈ្មោះរបស់អាជ្ញាធររដ្ឋ ។ ក្នុងករណីមួយ អ្នកសារព័ត៌មានម្នាក់ដែលត្រូវ បានចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នពាក់ព័ន្ធនឹងការរាយការណ៍ពីការធបោកតាមអនឡាញ។ អ្នកសារព័ត៌មានរូបនោះត្រូវបានដោះលែងឱ្យនៅក្រៅ ឃុំបណ្តោះអាសន្នវិញ បន្ទាប់ពីជាប់ឃុំអស់រយៈពេល ជាងពីរខែ ។

ក្នុងចំណោមការរំលោភបំពានទាំង ១២ ករណី មាន ៤ ករណីកើតឡើងបន្ទាប់ពីសេចក្តីរាយការណ៍ព័ត៌មានត្រូវបានចុះផ្សាយ ឬបង្ហោះលើបណ្តាញសង្គម ខណៈដែល ៨ ករណីទៀតកើតឡើងក្នុងអំឡុងពេលដែលអ្នកសារព័ត៌មានកំពុងចុះយកព័ត៌មាន ឬកំពុងរាយការណ៍នៅទីកន្លែងកើតហេតុ ។ ការរំលោភបំពានភាគច្រើនកើតឡើងនៅរាជធានីភ្នំពេញ ដែលស្មើនឹង ៦៧% នៃឧប្បត្តិហេតុសរុប ។

ដូចដែលខេមបូចាបានកត់ត្រាកន្លងមក អាជ្ញាធរៅនៅតែបន្តប្រើបទចោទព្រហ្មទណ្ឌដែលក្នុងនោះរួមមានបទញុះញង់ប្រឆាំងនឹងអ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហារសើប ជាជាងប្រើប្រាស់យន្តការស៊ីវិលដែលមានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន។ វិធីសាស្ត្របែបនេះ ផ្ទុយទៅនឹងស្តង់ដារច្បាប់អន្តរជាតិដែលការពារសេរីភាពបញ្ចេញមតិ ។ ការរឹតត្បិតលើការងារសារព័ត៌មានបែបនេះ បានរារាំងសាធារណជនពីការទទួលបានព័ត៌មាន និងធ្វើឱ្យចុះខ្សោយនូវការចូលរួមប្រកបដោយអត្ថន័យក្នុងការពិភាក្សាជាសាធារណៈ ។

២. សេចក្តីផ្តើម

ការដាក់ឱ្យអនុវត្តបទប្បញ្ញត្តិថ្មីៗពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ ការបង្ក្រាបផ្នែកនយោបាយ និងការរឹតត្បិតលើសេរីភាពបញ្ចេញមតិ បានរួមចំណែកធ្វើឱ្យសេរីភាពសារព័ត៌មានកម្ពុជានៅតែរងការរឹតត្បិត: ។ ប្រកាសស្តីពី «លក្ខខណ្ឌគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មានសម្រាប់អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាន និងសោតទស្សន៍» ដែលត្រូវបានដាក់ឱ្យអនុវត្តនៅចុងឆ្នាំ២០២៥ នៅតែជាក្តីកង្វល់ធំមួយសម្រាប់អ្នកសារព័ត៌មានឯករាជ្យ ជាពិសេសអ្នកសារព័ត៌មានដែលហ៊ានរាយការណ៍អំពីបញ្ហាសំខាន់ៗ ឬបញ្ហា ដែលមានភាពរសើបនៅកម្ពុជា ។

អ្នកសារព័ត៌មានបានាប្រឈមនឹងបញ្ហាក្នុងការទទួលបានបណ្ណសម្គាល់អ្នកសារព័ត៌មានពីក្រសួងព័ត៌មាន ចាប់តាំងពីប្រកាសថ្មីនេះត្រូវបានដាក់ឱ្យអនុវត្ត ។ ដោយសារគ្មានបណ្ណសារព័ត៌មាន ប្រភពព័ត៌មានជាច្រើនបដិសេធមិននិយាយជាមួយអ្នកសារព័ត៌មាន ដែលធ្វើឱ្យការអនុវត្តការងាររបស់ពួកគេកាន់តែលំបាក ហើយក្នុងករណីខ្លះ អ្នកសារព័ត៌មានឯករាជ្យត្រូវបង្ខំចិត្តលាក់អត្តសញ្ញាណរបស់ខ្លួននៅពេលចុះយកព័ត៌មាន ។

ជាមួយគ្នានេះដែរ ក្រសួងព័ត៌មាន បានចាប់ផ្តើមអនុវត្តដំណាក់កាលទី២ នៃយុទ្ធនាការ«និយាយថាទេ ចំពោះព័ត៌មានក្លែងក្លាយ[9]» នៅទូទាំងប្រទេស ក្នុងគោលបំណងលើកកម្ពស់អក្ខរកម្មព័ត៌មាន និងទប់ស្កាត់ព័ត៌មានក្លែងក្លាយ។ ដំណាក់កាលទី១ នៃយុទ្ធនាការនេះ ត្រូវបានចាប់ផ្តើមក្នុងឆ្នាំ២០២៥ ដើម្បីលើកកម្ពស់ការប្រើប្រាស់បណ្តាញសង្គមប្រកបដោយទំនួលខុសត្រូវ និងប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ[10]។

ដំណាក់កាលទី២នេះ បន្តអនុវត្តក្រោមការគាំទ្រពីរដ្ឋាភិបាលចិនតាមរយៈក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។ បន្ទាប់ពីបានផ្តល់ថវិកាចំនួន ១.៧លានដុល្លារអាមេរិកសម្រាប់ដំណាក់កាលទី១ ប្រទេសចិនបានផ្តល់ថវិកាបន្ថែមចំនួន ២៧០ ០០០ ដុល្លារអាមេរិកសម្រាប់ឆ្នាំ២០២៦នេះ[11]។

យោងតាមក្រសួងព័ត៌មាន កម្ពុជាមានគណនីហ្វេសប៊ុក (Facebook) ប្រមាណចំនួន១៥លានគណនី និងតិកតុក (TikTok) ជាង១០លានគណនី ដែលធ្វើឱ្យបណ្តាញសង្គមក្លាយជាប្រភពព័ត៌មានដ៏សំខាន់មួយនៅក្នុងប្រទេស ។ ក្នុងបរិបទនេះគណៈកម្មាធិការប្រឆាំងព័ត៌មានក្លែងក្លាយរបស់រដ្ឋាភិបាលបានអះអាងថាខ្លួនបានរកឃើញចំនួនព័ត៌មានក្លែងក្លាយជិត ៤០០០ករណី ក្នុងឆ្នាំ២០២៥។

ទោះជាយ៉ាងណាយុទ្ធនាការនេះបានបង្កឱ្យមានក្តីបារម្ភពីអ្នកការពារសេរីភាពសារព័ត៌មាន ដោយសារអាជ្ញាធរកម្ពុជាធ្លាប់បានប្រើការបកស្រាយយ៉ាងទូលំទូលាយ ឬមិនច្បាស់លាស់អំពីពាក្យថា «ព័ត៌មានក្លែងក្លាយ» ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការស៊ើបអង្កេត ការចាប់ខ្លួន និងចំណាត់ការផ្លូវច្បាប់ប្រឆាំងនឹងអ្នកសារព័ត៌មាន សកម្មជន និងបុគ្គលដែលបញ្ចេញមតិរិះគន់តាមអនឡាញ ។

នៅក្នុងលំហនយោបាយ អតីតមេដឹកនាំគណបក្សប្រឆាំង លោក កឹម សុខា ទទួលបានព្រះរាជទានការលើកលែងទោសនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦ ដោយបញ្ចប់ទោសជាប់ពន្ធនាគារ ២៧ ឆ្នាំ ៣ក់ព័ន្ធនឹងសំណុំរឿងអូសបន្លាយជាយូរមកហើយ[12]។ ទោះជាយ៉ាងណា លោកនៅតែត្រូវបានហាមឃាត់ពីការចូលរួមសកម្មភាពនយោបាយ។ ការលើកលែងទោសនេះ បានកើតឡើងស្របពេលដែលការរឹតត្បិតលើសិទ្ធិ

[9] https://cambojanews.com/say-no-to-fake-news-phase-ii-targets-youth-media-literacy/
[10] https://cambojanews.com/government-launches-to-anti-fake-news-campaign-opponents-fear-suppression-of-freedom-of-expression/
[11] https://cambojanews.com/china-funds-second-phase-of-information-ministry-anti-fake-news-campaign/

នយោបាយ និងលំហស៊ីវិលនៅតែបន្តកើតមានដែលរួមមានទាំងការចាប់ខ្លួនពាក់ព័ន្ធនឹងការរិះគន់តាមអនឡាញផងដែរ។

នៅថ្ងៃទី១៩ ខែមិថុនា តុលាការកំពូលនៅរាជធានីភ្នំពេញ បានតម្កល់សាលក្រមផ្តន្ទាទោសលោក រ៉ុង ឈុន ឱ្យជាប់ពន្ធនាគារយៈពេល៤ឆ្នាំប៉ុន្តែបានព្យួរការអនុវត្តទោស ។ តុលាការក៏បានហាមឃាត់លោកមិនឱ្យចូលរួមសកម្មភាពនយោបាយរយៈពេល៥ឆ្នាំ និងហាមធ្វើដំណើរចេញក្រៅរាជធានីភ្នំពេញផងដែរ[13]។

ជារួមការវិវឌ្ឍទាំងនេះអាចរួមចំណែកបង្កើតបរិយាកាសដែលកាន់តែរឹតត្បិតចំពោះសេរីភាពបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាននៅកម្ពុជា ។ ការពង្រីកកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋក្នុងការគ្រប់គ្រងមាតិកាអនឡាញគួបផ្សំនឹងការរឹតត្បិតផ្នែកនយោបាយដែលនៅតែបន្ត អាចជំរុញឱ្យមានការដាក់កំហិតលើខ្លួនឯងក្នុងចំណោមអ្នកសារព័ត៌មាន អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋជាពិសេសនៅពេលរាយការណ៍អំពីបញ្ហានយោបាយដែលមានភាពរសើប ឬបញ្ចេញមតិជំទាស់ ។ បរិយាកាសបែបនេះក៏អាចកាត់បន្ថយឱកាសសម្រាប់ការពិភាក្សាជាសាធារណៈដោយបើកចំហ និងកម្រិតភាពចម្រុះនៃសំឡេងក្នុងការពិភាក្សាអំពីបញ្ហាផលប្រយោជន៍សាធារណៈផងដែរ ។

របាយការណ៍ឃ្លាំមើលការរំលោភបំពានលើអ្នកសារព័ត៌មានរបស់ខេមបូចា ដើរតួនាទីយ៉ាងសំខាន់ក្នុងការចងក្រង និងវាយតម្លៃបរិយាកាសប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាសេរីភាពបញ្ចេញមតិនៅកម្ពុជា តាមរយៈការផ្តល់នូវការយល់ឃើញផ្នែកលើភស្តុតាង បង្ហាញក្តីកង្វល់ដែលនៅតែបន្តកើតមាន និងជំរុញឱ្យមានកំណែទម្រង់គោលនយោបាយប្រកបដោយអត្ថន័យ ដើម្បីការពារអ្នកសារព័ត៌មាន និងធានាបាននូវបរិយាកាសប្រព័ន្ធផ្សព្វផ្សាយដែលមានសេរីភាព និងសុវត្ថិភាព។ ការរកឃើញដែលបង្ហាញនៅក្នុងរបាយការណ៍នេះ បានធ្លុះបញ្ចាំងពីស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជាដែលនៅតែមាននិន្នការនៃការរឹតត្បិតលើការរាយការណ៍ព័ត៌មានដោយឯករាជ្យ។

ការរំលោភបំពានដែលត្រូវបានចងក្រងដោយខេមបូចា មិនត្រឹមតែរំលោភសិទ្ធិដែលបានធានាដោយរដ្ឋធម្មនុញ្ញកម្ពុជាទាក់ទងនឹងសេរីភាពសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយប៉ុណ្ណោះទេ ជាពិសេសមាត្រា៤១ ដែលចែងថាពលរដ្ឋខ្មែរមានសេរីភាពខាងបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងបោះពុម្ពផ្សាយ និងសេរីភាពខាងជួបជុំ ហើយមាត្រា ៣៨ ដែលធានាសេរីភាពស៊ីវិលជាមូលដ្ឋាន សុវត្ថិភាពរាងកាយ និងសិទ្ធិរបស់ជនជាប់ចោទក្នុងប្រព័ន្ធយុត្តិធម៌ ។ ការរំលោភបំពានទាំងនេះ ក៏ផ្ទុយទៅនឹងស្តង់ដារអន្តរជាតិក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលក្នុងនោះរួមមានសិទ្ធិជាមូលដ្ឋាននៃសេរីភាពបញ្ចេញមតិ សន្តិសុខរាងកាយ សិទ្ធិទទួលបានយុត្តិធម៌ សិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវ និងសេរីភាពផងដែរ។

ប្រសិនបើមិនមានវិធានការបញ្ឈប់ការប្រើប្រាស់ច្បាប់ដោយមិនត្រឹមត្រូវ លុបចោលបទប្បញ្ញត្តិដែលមានលក្ខណៈរឹតត្បិត និងការពារអ្នកសារព័ត៌មានពីការសងសឹកនានានោះទេ លំហសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា នឹងបន្តរួមតូចទៅ។ ដែលជាញឹកញាប់កើតឡើងដោយមិនសូវទទួលបានការចាប់អារម្មណ៍ពីសាធារណជន ហើយនឹងមានផលវិបាកធ្ងន់ធ្ងរចំពោះគណនេយ្យភាព និងអភិបាលកិច្ចបែបប្រជាធិបតេយ្យ។

[13] https://cambojanews.com/kem-sokhas-27-year-prison-sentence-pardoned-but-still-barred-from-politics/
[14] https://cambojanews.com/supreme-court-upholds-rong-chhun-conviction-but-suspends-prison-sentence/

៣. វិធីសាស្ត្រឃ្លាំមើលផ្អែកលើសិទ្ធិមនុស្ស

វិធីសាស្ត្រ និងការប្រមូលទិន្នន័យនៅក្នុងរបាយការណ៍នេះផ្តោតលើដំណោះស្រាយផ្អែកលើសិទ្ធិមនុស្ស ដើម្បីស្វែងយល់ និងឃ្លាំមើលការគំរាមកំហែង និងការវាយប្រហារមកលើសុវត្ថិភាពរបស់អ្នកសារព័ត៌មាន។

វិធីសាស្ត្រនេះទទួលស្គាល់ថាសកម្មភាពបែបនេះ មិនមែនត្រឹមតែប៉ះពាល់លើអ្នកសារព័ត៌មានជាលក្ខណៈបុគ្គលទេ ប៉ុន្តែជាការរំលោភលើសិទ្ធិជាមូលដ្ឋាន ដែលជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ និង ប្រកបដោយបរិយាប័ន្ន។ ដូច្នេះវិធីសាស្ត្រប្រមូលទិន្នន័យនេះគោរពតាមបទដ្ឋាន សិទ្ធិមនុស្សអន្តរជាតិ រួមមានការការពារសេរីភាពនៃការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិជាមូលដ្ឋានផ្សេងៗទៀត ដូចជាសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ដូចដែលមានចែងនៅក្នុងកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។ ចំណុចសំខាន់នៃ វិធីសាស្ត្រនេះ គឺការយល់ដឹង អំពីការទទួលខុស ត្រូវ របស់រដ្ឋ ក្នុងការគោរពការការពារ និងការបំពេញលក្ខខណ្ឌសិទ្ធិមនុស្សស្របតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ។ ការគំរាមកំហែង និងការវាយប្រហារដែលផ្តោតគោលដៅមកលើអ្នក សារព័ត៌ មាន និងស្ថាប័ន ព័ត៌មាន ដោយសារតែការបំពេញការងាររបស់ពួកគេត្រូវបានគេមើលឃើញថា ជាការរំលោភបំពានសិទ្ធិនៃការបញ្ចេញមតិ ហើយសកម្មភាពនេះក៏ប៉ះពាល់ដល់សិទ្ធិក្នុងការទទួល បានព័ត៌មាន របស់សាធារណជន ផងដែរ។

ដូច្នេះផ្នែកសំខាន់នៃក្របខណ្ឌឃ្លាំមើលនេះ គឺផ្តោតលើការកត់ត្រាការរំលោភលើសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងការរំលោភបំពានពាក់ព័ន្ធផ្សេងទៀតលើសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលមានសារៈសំខាន់ក្នុងការជួយអ្នកសារព័ត៌មានឱ្យបំពេញការងារដោយសេរី និង ដោយសុវត្ថិភាព ។

សិទ្ធិទាំងអស់នោះរួមមាន ៖

- សិទ្ធិក្នុងការរស់រានមានជីវិត
- ការការពារពីអំពើទារុណកម្ម និង ការប្រព្រឹត្តមកលើរាងកាយ ឬទណ្ឌកម្ម ឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ទោកបន្ទាប
- សិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន រួមទាំងការការពារ ពីការឃុំខ្លួនខុសនីតិវិធី
- សិទ្ធិទទួលបានដំណោះស្រាយសមរម្យ
- សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌
- ការការពារពីការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន
- សិទ្ធិទទួលបានសមភាព និងមិនមានការរើសអើង

ហេតុដូច្នេះ វិធីសាស្ត្រប្រមូលទិន្នន័យ នៃរបាយការណ៍នេះការកត់ត្រាការគំរាមកំហែង និងការវាយប្រហារមកលើអ្នកសារព័ត៌មាន ជាការរំលោភបំពានលើសិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការបញ្ចេញមតិ សិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយសំខាន់ៗផ្សេងទៀតដូចដែលបានលើកជាឧទាហរណ៍ខាងលើ។

វិធីសាស្ត្រប្រមូលទិន្នន័យនេះក៏អនុវត្តតាមសូចនាករស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន (JSIs) របស់អង្គការយូណេស្កូ និង ផែនការសកម្មភាពរបស់អង្គការសហប្រជាជាតិ ស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព (UNAP) ដែលជាគោលការណ៍អន្តរជាតិសំខាន់ៗដើម្បីវាយតម្លៃពីសុវត្ថិភាពរបស់អ្នកសារព័ត៌មានដោយរួមមានទិដ្ឋភាពច្បាប់ដែលទាក់ទងគ្នា សុវត្ថិភាពលើរាងកាយ ផ្លូវចិត្ត សុវត្ថិភាពអនឡាញ និង សុវត្ថិភាពផ្អែកលើយេនឌ័រ។ ផ្អែកលើគោលការណ៍ទាំងនេះ វិធីសាស្ត្រឃ្លាំមើលនេះបានរួមបញ្ចូលការយល់ដឹងផ្អែកយេនឌ័រ ដើម្បីបញ្ជាក់ថា ការគំរាមកំហែង និងការវាយប្រហារមកលើអ្នកសារព័ត៌មាន គឺជាការរំលោភបំពានសិទ្ធិមនុស្ស។

តើនរណា/អ្វីខ្លះ ត្រូវបានបញ្ចូលក្នុងទិន្នន័យនេះ?

ផ្អែកលើបទបញ្ញត្តិសិទ្ធិមនុស្សអន្តរជាតិ ការកំណត់និយមន័យដ៏ទូលំទូលាយ អំពីអ្នកសារព័ត៌មាន និង វិជ្ជាជីវៈសារព័ត៌មានត្រូវបានកំណត់ដោយគ្រប់ដណ្តប់លើ៖

1. បុគ្គលដែលពាក់ព័ន្ធនឹងសកម្មភាពនៃការងារសារព័ត៌មាន ដើម្បីផ្តល់ដំណឹងដល់សាធារណជន អំពីបញ្ហាសំខាន់ៗដែលជាប្រយោជន៍សាធារណៈ ។
2. រាល់សកម្មភាពទាំងឡាយណា ដែលសំដៅមកលើបុគ្គលទាំងនោះ ជាគោលដៅនៃការគំរាមកំហែង
3. ការបំភិតបំភ័យដោយសារតែសកម្មភាពសារព័ត៌មានរបស់ពួកគេគឺជា ការរំលោភលើ សិទ្ធិជាមូលដ្ឋាន ។

ការចាត់ថ្នាក់ នៃការរំលោភសិទ្ធិមនុស្ស

វិធីសាស្ត្រនេះគ្របដណ្តប់លើការរំលោភសិទ្ធិមនុស្សចំនួន៧ប្រភេទរួមមានការរំលោភលើសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសុវត្ថិភាពលើរាងកាយ សិទ្ធិទទួលបានសុវត្ថិភាពលើរាងកាយ និងសេរីភាព សិទ្ធិទទួលបានសុច្ឆរិតភាព ផ្លូវចិត្ត សិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវ និង សេរីភាពក៏ដូចជា ការរំលោភបំពានផ្សេងទៀតលើសេរីភាពនៃការបញ្ចេញមតិ។

ការរំលោភបំពាន ទាំងនេះក៏ត្រូវបានបែងចែងទៅតាមប្រភេទនៃការប្រព្រឹត្តបន្ថែមទៀតផងដែរ ដែលការប្រព្រឹត្តនោះ គឺស្ថិតក្នុងទម្រង់នៃការរំលោភបំពានសិទ្ធិមនុស្ស។ ពាក្យពេចន៍ដែលកំណត់នយច្បាស់លាស់ ត្រូវបានបង្កើតឡើងសម្រាប់ប្រើប្រាស់ក្នុងការចាត់ថ្នាក់ និង ការចាត់ថ្នាក់រង ជាប្រព័ន្ធចំពោះប្រភេទនៃការរំលោភបំពានទាំងនេះ ។ ពាក្យពេចន៍ទាំងនេះ គឺផ្អែកលើ បទដ្ឋានសិទ្ធិមនុស្ស និងដកស្រង់ចេញពីប្រភពចម្រុះ រួមមានការចាត់ថ្នាក់បទឧក្រិដ្ឋអន្តរជាតិរបស់អង្គការសហប្រជាជាតិសម្រាប់គោលបំណងស្ថិតិ (ICCS)[៦] សូចនាករនៃគោលដៅអភិវឌ្ឍប្រកបដោយ ចីរភាព (SDG) ១៦.១០.១[៧] និងបទបញ្ញត្តិសំខាន់ ៗ ដែលចែងអំពីសិទ្ធិមនុស្ស។[៨]

[៦] ការបែងចែកប្រភេទឧក្រិដ្ឋកម្មអន្តរជាតិ គឺជាក្របខ័ណ្ឌមួយដើម្បីបែងចែក និងចាត់ថ្នាក់ជាប្រព័ន្ធ ប្រភេទឧក្រិដ្ឋកម្ម សម្រាប់គោលបំណងនៃការប្រមូលទិន្នន័យ ការវិភាគ និង ការប្រៀបធៀបអន្តរជាតិ។ វាផ្តល់នូវវិធី សាស្ត្រស្តង់ដារសម្រាប់ចាត់ថ្នាក់ឧក្រិដ្ឋកម្មដល់ការគំទ្រ ការប្រៀបធៀបទិន្នន័យ។ ករណីដែលបានរួមបញ្ចូលនៅក្នុងរបាយការណ៍នេះ ស្ថិតក្នុងការចាត់ថ្នាក់ឧក្រិដ្ឋកម្មអន្តរជាតិ រួមមានការចាប់ពិរុទ្ធ (ICCS 08031) ការឃុំខ្លួនដោយបំពាន (ICCS 020222) ការបៀតបៀនផ្លូវច្បាប់ (ICCS 0806) ការរើសអើង (ICCS 0210) និងការរំលោភបំពាន (ICCS 02011)។

[៧] សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព 16.10.1 រាស់វែងការទទួលបានសិទ្ធិជាមូលដ្ឋានដែលត្រូបដណ្តប់ៈ «ចំនួនករណីដែលបានផ្ទៀងផ្ទាត់ការសម្លាប់ ការចាប់ពង្រត់ ការបាត់ខ្លួនដោយបង្ខំ ការឃុំខ្លួនតាមអំពើចិត្ត និងការធ្វើទារុណកម្មលើអ្នកសារព័ត៌មាន បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ដៃគឹពាក់ព័ន្ធ សហជីព និងអ្នកការពារ សិទ្ធិមនុស្សក្នុងរយៈពេល ១២ខែមុន។» សូមមើលៈhttps://www.ohchr.org/sites/default/files/Documents/Issues/HRIndicators/SDG_Indicator_16_10_1_ Guidance_Note.pdf

[៨] បទបញ្ញត្តិសិទ្ធិមនុស្សទាំងនេះរួមមាន: សេចក្តីប្រកាសជាសកលនៃសិទ្ធិមនុស្ស (UDHR) កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តិដ៏ឃោរឃៅ អមនុស្សធម៌ ឬថោកទាប (CAT)។

វាអាចត្រូវបានកត់សម្គាល់ថា ការរំលោភបំពានចំពោះអ្នកសារព័ត៌មានអាចមានលក្ខណៈច្រើនប្រភេទ នៃការរំលោភសិទ្ធិមនុស្ស (ឧ. ការឃុំខ្លួន និងការបំពានលើរាងកាយ)។ សម្រាប់គោលបំណងនៃការចាត់ ថ្នាក់ផ្នែកស្ថិតិ នៃករណីរំលោភបំពាន ខេមបូចាបានធ្វើការកំណត់អំពីប្រភេទសិទ្ធិមនុស្សដែលត្រូវបានរំលោភយ៉ាងធ្ងន់ធ្ងរបំផុត (ការរំលោភជាចម្បង)។ ព័ត៌មានអំពីការរំលោភបំពានបន្ថែម ឬការរំលោភបំពានពាក់ព័ន្ធផ្សេងទៀត ដែលអ្នកសារព័ត៌មានដដែលបានជួបប្រទះត្រូវបានកត់ត្រាទុកក្នុងប្រភពព័ត៌មានគុណភាព។

ការប្រមូល និងការផ្ទៀងផ្ទាត់ទិន្នន័យ

ទិន្នន័យស្តីពីការរំលោភបំពានសិទ្ធិមកលើអ្នកសារព័ត៌មាន ដែលបញ្ចូលក្នុងរបាយការណ៍នេះ ត្រូវបានប្រមូលដោយប្រើប្រាស់ព័ត៌មានចម្រុះទាំងពីប្រភពចម្បង និងប្រភពបន្ទាប់បន្សំ។ ទិន្នន័យពីប្រភពចម្បងត្រូវបានប្រមូលតាមរយៈបទសម្ភាសជាមួយជនរងគ្រោះ សមាជិកគ្រួសាររបស់ពួកគេ និងសាក្សីហើយត្រូវបានផ្ទៀងផ្ទាត់តាមរយៈការស្រាវជ្រាវឯកសារដែលមានស្រាប់។ ប្រភពបន្ទាប់បន្សំរួមមានសេចក្តីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានព័ត៌មាននៅលើបណ្តាញសង្គម និងឯកសារផ្លូវការរបស់តុលាការ។

ដើម្បីធានាបាននូវភាពត្រឹមត្រូវរាល់ទិន្នន័យទាំងអស់ត្រូវឆ្លងកាត់ដំណើរផ្ទៀងផ្ទាត់ជាមួយនឹងប្រភពច្រើន និងការត្រួតពិនិត្យជាប្រចាំ។ ក្នុងករណីដែលអ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីបទកំហែងយក ខេមបូចាបានចាត់ទុកករណីទាំងនេះថាជាករណី រំលោភសិទ្ធិមនុស្ស លុះត្រាតែ ក្រោយពីបានធ្វើការស៊ើបអង្កេតឯករាជ្យបានបង្ហាញនូវភស្តុតាងអំពីការគំរាមកំហែងការបំភិតបំភ័យ ឬសកម្មភាពផ្សេងទៀត ដែលសំដៅធ្វើឱ្យប៉ះពាល់ដល់សេរីភាពសារព័ត៌មាន។

នៅក្នុងហេតុផលអំពីសុវត្ថិភាព និងសន្តិសុខ ឈ្មោះអ្នកសារព័ត៌មាន ដែលរងផលប៉ះពាល់ និងប្រភពផ្សេងទៀតត្រូវបានដកចេញពីរបាយការណ៍នេះ ក្នុងករណីដែលព័ត៌មានទាំងនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

វិសាលភាព និងដែនកំណត់

របាយការណ៍នេះរាប់បញ្ចូលករណីរំលោភបំពានមកលើអ្នកសារព័ត៌មាន ដែលត្រូវបានកត់ត្រាតាមរយៈ កិច្ចប្រឹងប្រែងឃ្លាំមើលរបស់ខេមបូចាតែប៉ុណ្ណោះ។ ដូច្នេះរបាយការណ៍នេះមិនបានគ្រប់ដណ្តប់លើករណីរំលោភបំពានទាំងអស់ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាអំឡុងពេលចងក្រងរបាយការណ៍នេះ ពីខែមករា ដល់ ខែមីនា ឆ្នាំ២០២៦ នោះទេ។

វាក៏ប្រហែលជាមានករណីច្រើនទៀតដែលគេមិនបានរាយការណ៍ ជាពិសេសនៅតាមតំបន់មួយចំនួន នៅ តាមខេត្ត ទីដែលអ្នកសារព័ត៌មានជារឿយៗប្រឈមនឹងការយាយីដោយគ្មានការឃ្លាំមើលការគាំទ្រ និង យន្តការការពារគ្រប់គ្រាន់។ ដូច្នេះលទ្ធផលដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះគ្រាន់តែជាផ្នែកមួយ ប៉ុណ្ណោះ ប៉ុន្តែជាព័ត៌មានឆ្លុះបញ្ចាំងអំពីនិន្នាការទូលំទូលាយ និងហានិភ័យដែលអ្នកសារព័ត៌មាននៅកម្ពុជាកំពុងប្រឈម។

សេរីភាពនៃការបញ្ចេញមតិ គឺជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ វាធានាថា បុគ្គលម្នាក់ៗអាចសម្តែងមតិទទួលបានព័ត៌មាន និងដាក់ឱ្យអ្នកមានអំណាចទទួលខុសត្រូវ ដោយគ្មានការភ័យខ្លាចអំពីការចាប់ពិរុទ្ធ ឬការសងសឹក។ នៅពេលដែលសារព័ត៌មានត្រូវបានចាប់ពិរុទ្ធ ឬរឹតត្បិត វាបង្កើតឱ្យមានការរំលោភបំពានដោយផ្ទាល់លើសិទ្ធិជាមូលដ្ឋាន ដែលត្រូវបានធានាក្នុងមាត្រា១៩ ទាំងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ (UDHR មាត្រា ១៩ ICCPR មាត្រា១៩ (១); ១៩ (២))

មាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR)

មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់។ សិទ្ធិនេះ រាប់ទាំងសេរីភាពក្នុងការប្រកាន់យកមតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយបញ្ចេញមតិបែបណាមួយក៏ដោយ។

មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

1. មនុស្សគ្រប់រូបមានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។
2. មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំង សេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយៈផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។
3. ការប្រើប្រាស់សិទ្ធិ ដែលមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិvអាចមានការរឹតត្បិតមួយចំនួន ដែលត្រូវកំណត់ជាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី៖
   (ក) គោរពសិទ្ធិ និងកិត្តិសព្ទអ្នកដទៃ។
   (ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។

៤. ការរកឃើញសំខាន់ៗ

ចាប់ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៦ ខេមបូចា បានចងក្រងការរំលោភសិទ្ធិមនុស្សចំនួន ១២ ករណី ដែលមានគោលដៅលើអ្នកសារព័ត៌មាន រួមមានអ្នកសារព័ត៌មានជាស្ត្រី ៤ នាក់ អ្នកសារព័ត៌មានបរទេស ១នាក់ និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ១ នាក់)។ ការរំលោភបំពានទាំង ១២ករណីនេះ បានកើត ឡើងក្នុងឧប្បត្តិហេតុចំនួន១០ផ្សេងគ្នា ដែលមានន័យថា អ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ ចំនួន៨នាក់ បានរងនូវការរំលោភសិទ្ធិមនុស្សក្នុងឧប្បត្តិហេតុចំនួន ២ ដូចគ្នា។

ក្នុងចំណោមការរំលោភបំពានដែលបានចងក្រងករណីចំនួន៨ កើតឡើងបន្ទាប់ពីព័ត៌មានត្រូវបានផ្សព្វផ្សាយ ឬបង្ហោះលើបណ្តាញសង្គម ខណៈដែល ៨ ករណីទៀតបានកើតឡើងអំឡុងពេលអ្នកសារព័ត៌មានកំពុងចុះយកព័ត៌មាន ឬកំពុងរាយការណ៍នៅទីតាំងកើតហេតុ ។ ក្នុងចំណោមឧប្បត្តិហេតុទាំងនេះ មាន ៣ករណីដែលអ្នកសារព័ត៌មានប្រឈមនឹងការរំលោភបំពានខណៈពេលកំពុងរាយការណ៍ពីការតវ៉ានៅទីតាំងសាធារណៈ។ ករណីភាគច្រើនបានកើតឡើងនៅរាជធានីភ្នំពេញដែលស្មើនឹង៦៧% នៃឧប្បត្តិហេតុសរុប ។

ករណីនៃការរំលោភបំពានដែលត្រូវបានកត់ត្រាក្នុងត្រីមាសនេះ បានកើនឡើង៩% បើធៀបនឹងត្រីមាសមុន (ខែមករាដល់ខែមីនា ឆ្នាំ២០២៦) ដែលមានការរំលោភបំពានចំនួន ១១ករណី។

ទិន្នន័យបង្ហាញថាការបំភិតបំភ័យ និងវិធានការផ្លូវច្បាប់នៅតែជាក្តីកង្វល់។ ក្នុងចំណោមការរំលោភបំពានទាំង ១២ ករណី ដែលបានចងក្រងក្នុងត្រីមាសនេះ មាន ៤ ករណីប៉ះពាល់ដោយផ្ទាល់ដល់សុវត្ថិភាពផ្លូវច្បាប់របស់អ្នកសារព័ត៌មាន (សូមមើលតារាងទី១)។ ករណីទាំងនេះរួមមានការឃុំខ្លួនរយៈពេលខ្លីចំនួន ៣ករណី ដែលក្នុងនោះមានអ្នកសារព័ត៌មានជាស្ត្រីម្នាក់ត្រូវបានឃុំខ្លួនដោយនគរបាលរយៈពេល ៧២ ម៉ោង បន្ទាប់ពីរាយការណ៍អំពីមន្ទីរពេទ្យធំមួយនៅរាជធានីភ្នំពេញ ។

ក្នុងករណីមួយទៀតនៃការបំភិតបំភ័យតាមផ្លូវច្បាប់ អ្នកសារព័ត៌មានម្នាក់ត្រូវបាននគរបាល ឃាត់ខ្លួន ខណៈពេលកំពុងយកព័ត៌មានពីការតវ៉ានៅមុខស្ថានទូតចិន ។ អ្នកសារព័ត៌មានអនឡាញម្នាក់ទៀត ត្រូវបានចាប់ខ្លួនដោយនគរបាលខេត្តដោយគ្មានការបញ្ជាក់មូលហេតុច្បាស់លាស់ ហើយត្រូវបានបញ្ជូនទៅតុលាការដើម្បីសួរចម្លើយ ៣ក់ព័ន្ធនឹងការអត្ថាធិប្បាយដែលបានបង្ហោះលើបណ្តាញសង្គមទាក់ទងរឿងពុករលួយ។ បន្ថែមពីនេះ អ្នកសារព័ត៌មានម្នាក់ទៀតត្រូវបានកោះហៅឱ្យចូលបំភ្លឺ និងត្រូវបានសួរចម្លើយអស់រយៈពេល ៧ម៉ោងដោយនគរបាលខេត្ត បន្ទាប់ពីរាយការណ៍អំពីការឃាត់ខ្លួន ជនជាតិចិនមួយក្រុម ក្នុងអំឡុងពេលប្រតិបត្តិការបង្ក្រាបជនអន្តោប្រវេសន៍ខុសច្បាប់នៅក្នុងខេត្តមួយ ។

ការរំលោភបំពានមួយករណី ៣ក់ព័ន្ធនឹងការបំពានរាងកាយលើអ្នកសារព័ត៌មានម្នាក់ ដែលត្រូវបានវាយប្រហារដោយបុគ្គលម្នាក់ ខណៈពេលកំពុងថតរូបពីសកម្មភាពដែលសង្ស័យថាជការដឹកឈើខុសច្បាប់។ ក្នុងករណីមួយផ្សេងទៀត អ្នកសារព័ត៌មានម្នាក់ត្រូវបានគំរាមកំហែងមកលើរាងកាយ ខណៈពេលកំពុងរាយការណ៍អំពីការចោទប្រកាន់ថាមានការនាំទំនិញថៃចូលកម្ពុជា តាមច្រកព្រំដែនមួយពីប្រទេសឡាវ ។

តារាងបង្ហាញពីចំនួនករណីរំលោភសិទ្ធិប្រឆាំងអ្នកសារព័ត៌មាន (មេសា-មិថុនា)



ការរំលោភបំពានចំនួន ៤ករណីដែលបានកត់ត្រា ៣ក់ព័ន្ធនឹងការឹតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិរបស់អ្នកសារព័ត៌មាន ខណៈពេលពួកគេកំពុងរាយការណ៍ពីព្រឹត្តិការណ៍នៅទីសាធារណៈ ។ ការឹតត្បិតទាំងនេះរួមមានការបដិសេធមិនអនុញ្ញាតឱ្យចូលទៅកាន់ទីតាំងយកព័ត៌មាន ការបំភិតបំភ័យតាមរយៈការព្រមានមិនឱ្យបន្តរាយការណ៍លើប្រធានបទរសើប និងការបង្ខំឱ្យលុបមាតិកាសារព័ត៌មាន ដែលក្នុង នោះរួមមានការបង្ខំឱ្យលុបរូបថតដែលថតបានក្នុងអំឡុងពេលយកព័ត៌មាន ។

ប្រធានបទដែលនាំឱ្យមានករណីរំលោភសិទ្ធិប្រឆាំងអ្នកសារព័ត៌មាន (មេសា-មិថុនា)



ការរកឃើញក្នុងត្រីមាសនេះ បង្ហាញថាអ្នកសារព័ត៌មានដែលធ្វើការឱ្យស្ថាប័នប្រព័ន្ធផ្សព្វផ្សាយអនឡាញនៅ តែជាក្រុមដែលប្រឈមនឹងការរំលោភបំពានច្រើនដូចគ្នានឹងត្រីមាសមុនដែរ ។ ស្ថិតិទាំងនេះ ស្របទៅនឹងនិន្នាការ កើនឡើងនៃការឃ្លាំមើលតាមអនឡាញ និងហានិភ័យកាន់តែកើនឡើងពាក់ព័ន្ធនឹងការប្រើប្រាស់វេទិកាឌីជីថល សម្រាប់ការរាយការណ៍ព័ត៌មានដោយឯករាជ្យ។

តួអង្គដែលមានទំនួលខុសត្រូវសម្រាប់ករណីរំលោភសិទ្ធិ (មេសា-មិថុនា)



ការរំលោភបំពានដែលបានចងក្រង បានកើតមានបន្ទាប់ពីការរាយការណ៍លើប្រធានបទរសើប រួមមាន ការ ឆបោកតាមអនឡាញ អំពើពុករលួយ សិទ្ធិមនុស្ស និងបរិស្ថាន។

ក្នុងចំណោមការរំលោភបំពានទាំង ១២ ករណី មាន ៨ ករណី ដែលត្រូវបានចោទប្រកាន់ថាពាក់ព័ន្ធនឹងតួអង្គរដ្ឋ ។ តួអង្គទាំងនេះ រួមមានអាជ្ញាធរថ្នាក់ជាតិ (កម្រិតក្រសួង) ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន (នគរបាល) ។ ករណីចំនួន ៣ពាក់ព័ន្ធនឹងបុគ្គលឯកជន (អ្នកជំនួញម្នាក់) ខណៈករណី ១ ទៀតត្រូវបានប្រព្រឹត្តដោយជនមិនស្គាល់ អត្តសញ្ញាណ (ជនរងគ្រោះមិនអាចកំណត់អត្តសញ្ញាណជនប្រព្រឹត្តនោះបានទេ) ។ អ្នកសារព័ត៌មានចំនួន ៦នាក់ ក្នុងចំណោមអ្នករងផលប៉ះពាល់ ធ្លាប់ជួបប្រទះការរំលោភបំពានទាក់ទងនឹងការងាររបស់ខ្លួនពីមុខ ។

ការរំលោភបំពានដែលបានកត់ត្រា បានបង្កឱ្យមានផលប៉ះពាល់ជាច្រើនដល់អ្នកសារព័ត៌មានម្នាក់ៗ រាប់ចាប់ពី ការបង្ខំឱ្យទទួលស្គាល់កំហុស ការចុះហត្ថលេខាលើលិខិតសុំទោសការរឹតត្បិតសេរីភាពក្នុងការធ្វើដំណើរ ភាព តានតឹងផ្លូវចិត្ត ការរឹតត្បិត លើខ្លួនឯង និងការបង្ខំឱ្យលុបមាតិកាព័ត៌មានជាដើម ។ ក្នុងចំណោមករណីដែលបាន ចងក្រងទាំង១២ មាន៧ ករណីដែលអ្នកសារព័ត៌មានត្រូវបានបង្ខំឱ្យលុបមាតិកាពាក់ព័ន្ធនឹងការរាយការណ៍របស់ ខ្លួន។

ក្នុងចំណោមករណីរំលោភបំពានដែលបានកត់ត្រាទាំង១២ មាន ៨ករណីបានបញ្ចប់ ដោយអាជ្ញាធរមិនបាន ចាត់វិធានការបន្ថែមលើអ្នកសារព័ត៌មានទៀតឡើយ បន្ទាប់ពីអ្នកសារព័ត៌មានបានអនុវត្តតាមការទាមទាររបស់ អាជ្ញាធរ ដូចជាការទទួលស្គាល់កំហុស ការចេញសុំទោសជាសាធារណៈ ការដកមាតិកាដែលបានផ្សព្វផ្សាយ រួចហើយ ឬការលុបរូបថត ។ ករណីចំនួន២ នៅតែស្ថិតក្នុងដំណើរការ ដោយអ្នកសារព័ត៌មានកំពុងរង់ចាំលទ្ធផល បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនទៅតុលាការ ។ ករណី២ផ្សេងទៀត ត្រូវបានបិទបញ្ចប់ បន្ទាប់ពីអ្នកសារព័ត៌មាន និងអ្នកដែលត្រូវបានចោទប្រកាន់ជាអ្នកប្រព្រឹត្តការរំលោភបំពានបានឈានដល់កិច្ចព្រមព្រៀងបញ្ចប់វិវាទ ។

ដូចដែលបានបង្ហាញក្នុងតារាងទី១ ការរំលោភបំពានដែលបានចងក្រងក្នុងអំឡុងពេលនេះ គ្របដណ្តប់លើ ទិដ្ឋភាពសុវត្ថិភាពសំខាន់ៗចំនួន៤ រួមមាន សុវត្ថិភាពផ្លូវច្បាប់ សុវត្ថិភាពរាងកាយ សុវត្ថិភាពផ្លូវចិត្ត និង ការរំលោភបំពានផ្សេងៗទៀតលើសិទ្ធិសេរីភាពបញ្ចេញមតិ ។

តារាងទី ១៖ ការបែងចែកការរំលោភបំពានតាមទិដ្ឋភាពសុវត្ថិភាព (មេសា-មិថុនា ២០២៦)

ទិដ្ឋភាពសុវត្ថិភាព	ចំនួនការរំលោភបំពានសិទ្ធិ	ចំនួនឧប្បត្តិហេតុ
សុវត្ថិភាពផ្លូវច្បាប់	៤	៤
សុវត្ថិភាពរាងកាយ	២	២
សុវត្ថិភាពផ្លូវចិត្ត	២	២
ការរំលោភបំពានផ្សេងៗលើសិទ្ធិសេរីភាពបញ្ចេញមតិ	៤	២
សរុប	**១២**	**១០**

ក្នុងចំណោមករណីរំលោភបំពានដែលបានកត់ត្រាទាំង១២ មាន ៨ករណីបានបញ្ចប់ ដោយអាជ្ញាធរមិនបានចាត់វិធានការបន្ថែមលើអ្នកសារព័ត៌មានទៀតឡើយ បន្ទាប់ពីអ្នកសារព័ត៌មានបានអនុវត្តតាមការទាមទាររបស់អាជ្ញាធរ ដូចជាការទទួលស្គាល់កំហុស ការចេញសុំទោសជាសាធារណៈ ការដកមាតិកាដែលបានផ្សព្វផ្សាយរួចហើយ ឬការលុបរូបថត ។ ករណីចំនួន២ នៅតែស្ថិតក្នុងដំណើរការ ដោយអ្នកសារព័ត៌មានកំពុងរង់ចាំលទ្ធផលបន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនទៅតុលាការ ។ ករណី២ផ្សេងទៀត ត្រូវបានបិទបញ្ចប់ បន្ទាប់ពីអ្នកសារព័ត៌មាន និងអ្នកដែលត្រូវបានចោទប្រកាន់ជាអ្នកប្រព្រឹត្តការរំលោភបំពានបានឈានដល់កិច្ចព្រមព្រៀងបញ្ចប់វិវាទ ។

ដូចដែលបានបង្ហាញក្នុងតារាងទី១ ការរំលោភបំពានដែលបានចងក្រងក្នុងអំឡុងពេលនេះ គ្របដណ្តប់លើទិដ្ឋភាពសុវត្ថិភាពសំខាន់ៗចំនួន៤ រួមមាន សុវត្ថិភាពផ្លូវច្បាប់ សុវត្ថិភាពរាងកាយ សុវត្ថិភាពផ្លូវចិត្ត និងការរំលោភបំពានផ្សេងៗទៀតលើសិទ្ធិសេរីភាពបញ្ចេញមតិ ។

តារាងទី២៖ ប្រភេទ នៃការរំលោភសិទ្ធិមនុស្ស និងសកម្មភាពដែលបានកត់ត្រា (មេសា-មិថុនា ២០២៦)

ប្រភេទនៃការរំលោភសិទ្ធិមនុស្ស	សកម្មភាពដែលត្រូវបានរាប់បញ្ចូល	ប្រភេទនៃសកម្មភាព	ចំនួនការរំលោភបំពាន
សិទ្ធិទទួលបានសុខុមាលភាពផ្លូវចិត្ត	សកម្មភាពទាក់ទងនឹងការងារសារព័ត៌មាន ដែលមានបំណងបង្កការភ័យខ្លាច ឬភាពតានតឹងផ្លូវចិត្ត	ការបំភិតបំភ័យ	២
សិទ្ធិទទួលបានសន្តិសុខរាងកាយ	សកម្មភាពទាក់ទងនឹងការងារសារព័ត៌មាន ដែលបង្កឱ្យមានរបួសរាងកាយ ឬមានបំណង(គំរាម)បង្កគ្រោះថ្នាក់ដល់រា	ការវាយប្រហារ	១
		ការគំរាមកំហែងបង្កគ្រោះថ្នាក់ដល់រាងកាយ	១
សិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវ និងសេរីភាព	វិធានការផ្លូវច្បាប់តាមអំពើចិត្តដែលមានគោលបំណងបំបាក់ទឹកចិត្ត រឹតត្បិត ឬគ្រប់គ្រងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន	ការឃុំខ្លួន	៣
		ការកោះហៅ/សួរចម្លើយ	១
ការរំលោភបំពានផ្សេងៗលើសិទ្ធិសេរីភាពបញ្ចេញមតិ	សកម្មភាពដែលជាការត្រួតពិនិត្យ ឬគ្រប់គ្រងការបញ្ចេញមតិខាងសារព័ត៌មាន ដែលមិនស្ថិតក្នុងប្រភេទខាងលើ	មិនអនុញ្ញាតឱ្យចូល	២
		ការរារាំង ឬលុបខ្លឹមសារ	២
សរុប			**១២**

ការរំលោភបំពានត្រូវបានកត់ត្រានៅតាមរាជធានី-ខេត្តមួយចំនួន រួមមាន រាជធានីភ្នំពេញ ខេត្តតាកែវ រតនគិរី កោះកុង និងព្រះវិហារ (សូមមើលក្រាហ្វិកផែនទី)។

ទីតាំងដែលមានករណីរំលោភសិទ្ធិជអ្នកសារព័ត៌មានញឹកញាប់បំផុតក្នុងត្រីមាសនេះ



៥. បច្ចុប្បន្នភាពករណីដែលបានចងក្រងពីមុន

១. អ្នកសារព័ត៌មានម្នាក់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នបន្ទាប់ពីជាប់ឃុំបណ្តោះអាសន្នរយៈពេលពីរខែ

អ្នកសារព័ត៌មានអនឡាញម្នាក់នៅខេត្តបន្ទាយមានជ័យដែលត្រូវបានចាប់ខ្លួនកាលពីខែកុម្ភៈបន្ទាប់ពីរាយការណ៍ពីសកម្មភាពសង្ស័យពាក់ព័ន្ធនឹងការឆបោកតាមអនឡាញ ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នា ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ បន្ទាប់ពីជាប់ឃុំបណ្តោះអាសន្នអស់រយៈពេលជាងពីរខែ ។

អ្នកសារព័ត៌មានរូបនោះ គឺលោក ហែម វណ្ណា ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដោយកងរាជអាវុធហត្ថក្រុងប៉ោយប៉ែត បន្ទាប់ពីលោកបានរាយការណ៍អំពីទីតាំងសង្ស័យពាក់ព័ន្ធនឹងការឆបោកតាមអនឡាញនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ ក្រោយមក លោកត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ តាមមាត្រា ៤៩៥ និងបទលួចស្តាប់ ឬថតសំឡេងឯកជនតាមមាត្រា ៣០១ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

នៅថ្ងៃទី២៦ ខែមីនា សាលាឧទ្ធរណ៍ខេត្តបាត់ដំបង បានបើកសវនាការលើសំណើសុំដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន។ ទោះជាយ៉ាងណា នៅថ្ងៃទី២ ខែមេសា តុលាការបានបដិសេធសំណើនេះ។ ក្រោយមក សវនាការមួយទៀតត្រូវបានធ្វើឡើងនៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៦ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដែលតុលាការបានសម្រេចអនុញ្ញាតឱ្យដោះលែងលោកឱ្យនៅក្រៅឃុំបណ្តោះអាសន្ន។ លោក វណ្ណា ត្រូវបានដោះលែងនៅរសៀលថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦។

មុនពេលត្រូវបានចាប់ខ្លួន លោក វណ្ណា ត្រូវបានកងរាជអាវុធហត្ថក្រុងប៉ោយប៉ែត កោះហៅដោយមិនបានប្រាប់ពីមូលហេតុ។ បន្ទាប់មកលោកត្រូវបានបញ្ជូនទៅកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ពាក់ព័ន្ធនឹងការចោទប្រកាន់ថាបានផ្សព្វផ្សាយព័ត៌មានបំភាន់សាធារណៈពីការឆបោកតាមអនឡាញ។



លោក ហែម វណ្ណា ឈរនៅក្រៅតុលាការដំបូងខេត្តបន្ទាយមានជ័យរង់ចាំសវនាការ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦។(រូបថត៖ ហ្វេកប៊ុក អាដហុក)

២. តុលាការកំពូលតម្កល់សាលក្រមផ្តន្ទាទោសអ្នកសារព័ត៌មានពីរនាក់ឱ្យជាប់ពន្ធនាគារ ១៤ឆ្នាំ



រថយន្តរ៉ឺចាំដឹកអ្នកសារព័ត៌មានលោក ផន សុភាព និង ភាព ភារ៉ា ទៅពន្ធនាគារខេត្តសៀមរាប បន្ទាប់ពីសវនាការនៅតុលាការកំពូលបានបញ្ចប់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦។(រូបថត៖ អ៊ឹម ណារ៉ែន)

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ តុលាការកំពូលបានតម្កល់សាលក្រមរបស់សាលាឧទ្ធរណ៍ខេត្តបាត់ដំបង ដែលបានសម្រេចផ្តន្ទាទោសអ្នកសារព័ត៌មាន ផន សុភាព និង ភាព ភារ៉ា ឱ្យជាប់ពន្ធនាគារ រយៈពេល ១៤ឆ្នាំ ។

អ្នកសារព័ត៌មានទាំងពីររូបនេះ ត្រូវបានសាលាដំបូងខេត្តសៀមរាប ផ្តន្ទាទោសនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ ឱ្យជាប់ពន្ធនាគារ រយៈពេល ១៤ ឆ្នាំ ក្រោមបទចោទផ្តល់ឱ្យរដ្ឋបរទេសនូវព័ត៌មាន ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការការពារជាតិ ។ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ សាលាឧទ្ធរណ៍ខេត្តបាត់ដំបង បានតម្កល់សាលក្រមរបស់សាលាដំបូងខេត្តសៀមរាប ។

តុលាការកំពូលបានបើកសវនាការលើសំណុំរឿងនេះ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦ និងបានចេញសាលដីកានៅថ្ងៃទី២៥ ខែមិថុនា បានតម្កល់សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ខេត្តបាត់ដំបងដដែល ។

អ្នកស្រី ព្រហ្ម យ៉ន ម្តាយរបស់លោក សុភាព បានបដិសេធដោយទឹកភ្នែកថាកូនប្រុសរបស់ខ្លួនមិនបានក្បត់ជាតិ ឬផ្តល់ព័ត៌មានទៅឱ្យបរទេសឡើយ ។ អ្នកស្រីបានពណ៌នាថា លោក សុភាព ជាអ្នកសារព័ត៌មានម្នាក់ដែលតែងតែរាយការណ៍អំពីបញ្ហាសង្គម ហើយប្រសិនបើមានកំហុសអ្វីកើតឡើង ក៏ជាកំហុសដោយអចេតនាប៉ុណ្ណោះ ។

អ្នកស្រីបានថ្លែងថា៖ «ខ្ញុំសូមអំពាវនាវដល់តុលាការ និងរាជរដ្ឋាភិបាល មេត្តាបន្ធូរបន្ថយទោសដល់កូនប្រុសខ្ញុំផង ព្រោះគាត់មិនបានធ្វើរឿងនេះដោយចេតនាឡើយ ។ គាត់បានបែកបាក់ពីប្រពន្ធ និងកូនៗ ហើយពួកយើងក៏មានវ័យចាស់ជរាហើយ ។ សូមមេត្តាដោះលែងកូនខ្ញុំផង» ។

ភរិយារបស់លោក សុភាព គឺអ្នកស្រី ហុង ថា ក៏បានស្នើសុំស្រដៀងគ្នានឹងម្តាយក្មេករបស់ខ្លួនដែរ។ អ្នកស្រីបាននិយាយថា៖ «គាត់ស្គមជាងមុនណាស់ ។ គាត់ជាអ្នកសារព័ត៌មានល្អម្នាក់ ។ ខ្ញុំសង្ឃឹមថា ថ្នាក់ដឹកនាំ និងតុលាការ នឹងជួយបន្ធូរបន្ថយទោសនេះ ព្រោះស្វាមីខ្ញុំជាមនុស្សស្លូតបូតណាស់» ។

អ្នកនាំពាក្យក្រសួងព័ត៌មាន លោក ទេព អស្នារិទ្ធ បានមានប្រសាសន៍ថា អ្នកសារព័ត៌មាន «ត្រូវតែបែងចែកឱ្យដាច់រវាងការងារសារព័ត៌មាន និងសន្តិសុខជាតិ» ហើយគួរតែជៀសវាងសកម្មភាពដែលផ្ទុយនឹងច្បាប់ ។ លោកបានបន្ថែមថាក្រសួងព័ត៌មានបានផ្តល់ការគាំទ្រ និងធ្វើអន្តរាគមន៍ទាំងមុន និងក្នុងអំឡុងពេលដំណើរការនីតិវិធីផ្លូវច្បាប់ ។

៦. សេចក្តីសន្និដ្ឋាន

ការរកឃើញពីការឃ្លាំមើលរបស់ខេមបូចា ក្នុងត្រីមាសទី២ ឆ្នាំ២០២៦ បង្ហាញថា អ្នកសារព័ត៌មាននៅកម្ពុជា នៅតែបន្តប្រឈមនឹងបញ្ហាក្នុងការបំពេញការងាររបស់ពួកគេប្រកបដោយសុវត្ថិភាព និងឯករាជ្យ ។ ការរំលោភបំពានដែលបានចងក្រងបង្ហាញថា ការបំភិតបំភ័យផ្លូវច្បាប់ ការរឹតត្បិតលើការធ្វើសេចក្តីរាយការណ៍ ការបង្កគ្រោះថ្នាក់ដល់រាងកាយ និងសម្ភាធផ្លូវចិត្ត នៅតែជាឧបសគ្គដែលបន្តរារាំងសេរីភាពសារព័ត៌មាន ។ ជារួម ការបំពានទាំងនេះបានបង្កើតបរិយាកាសនៃការភ័យខ្លាច និងការដាក់រឹតត្បិតលើខ្លួនឯងដែលបានកម្រិតពីលទ្ធភាព របស់អ្នកសារព័ត៌មានក្នុងការរាយការណ៍ពីបញ្ហាផលប្រយោជន៍សាធារណៈ ។

ការបំភិតបំភ័យតាមផ្លូវច្បាប់ នៅតែជាទម្រង់នៃការរំលោភបំពានដែលកើតមានញឹកញាប់ជាងគេ តាមរយៈទម្រង់នៃការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌ ជាបន្តបន្ទាប់ប្រឆាំងនឹងអ្នកសារព័ត៌មានដែលរាយ ការណ៍ពីប្រធានបទរសើប ជាជាងការប្រើប្រាស់យន្តការការពារ និងដំណោះស្រាយដែលមានចែង ក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ។ អ្នកសារព័ត៌មានដែលរាយការណ៍ពីបញ្ហាដូចជាការឆបោកតាម អនឡាញ អំពើពុករលួយ និងបញ្ហាពាក់ព័ន្ធនឹងបុគ្គលមានឥទ្ធិពល នៅតែប្រឈមនឹងការចាប់ខ្លួន ការចោទប្រកាន់ ការដាក់សម្ភាធឱ្យលុបព័ត៌មានដែលបានផ្សព្វផ្សាយហើយ និងទម្រង់នៃការបំភិតបំភ័យ ផ្សេងៗដែលបង្អាក់ការរាយការណ៍ព័ត៌មានដោយឯករាជ្យ ។

ការវិវឌ្ឍថ្មីៗនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ ក៏បានបន្ថែមក្តីកង្វល់ទាំងនេះឱ្យកាន់តែធ្ងន់ធ្ងរផងដែរ ។ ការអនុវត្តបទប្បញ្ញត្តិថ្មីៗទាក់ទងនឹងការទទួលបានបណ្ណអ្នកសារព័ត៌មានថ្មីបានបង្កើតឧបសគ្គបន្ថែម ទៀតសម្រាប់អ្នកសារព័ត៌មាន ខណៈដែលកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងអ្វីដែលត្រូវបាន ហៅថា «ព័ត៌មានក្លែងក្លាយ» កាន់តែខ្លាំងដែលការណ៍នេះបានបង្កឱ្យមានការព្រួយបារម្ភថាវិធានការ អនុវត្តដែលមានការបកស្រាយទូលំទូលាយអាចត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតការងារសារព័ត៌មានស្របច្បាប់ និងការបញ្ចេញមតិរិះគន់ស្ថាបនា ។ គួបផ្សំជាមួយនឹងការបន្តរួមតូចនៃលំហពលរដ្ឋ និងនយោបាយ ការវិវឌ្ឍទាំងនេះអាចនាំឱ្យមានការរឹតត្បិតកាន់តែខ្លាំងលើសិទ្ធិទទួលបានព័ត៌មាន និងកាត់បន្ថយឱកាសសម្រាប់ការពិភាក្សាជាសាធារណៈដោយបើកចំហ ។

ការរកឃើញក្នុងរបាយការណ៍នេះ ក៏បង្ហាញផងដែរថា តួអង្គរដ្ឋ ជាពិសេសអាជ្ញាធរថ្នាក់មូលដ្ឋាន នៅតែជាអ្នកដែលត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវចម្បងចំពោះការរំលោភបំពានលើអ្នកសារព័ត៌មាន ។ កង្វះគណនេយ្យភាពចំពោះសកម្មភាពទាំងនេះបានរួមចំណែកបង្កើតបរិយាកាសនិរទណ្ឌភាព ដែលបង្កើនហានិភ័យនៃការរំលោភបំពានបន្ថែមទៀត និងបំផ្លាញទំនុកចិត្តរបស់សាធារណជនលើការការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋាន។

ការរំលោភបំពានដែលបានកត់ត្រាក្នុងអំឡុងពេលរាយការណ៍នេះ គឺផ្ទុយនឹងរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានធានានូវសេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន ព្រមទាំងផ្ទុយនឹងកាតព្វកិច្ចរបស់កម្ពុជាក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។ ការការពារអ្នកសារព័ត៌មានពីការបំភិតបំភ័យ និងពីការសងសឹក មិនត្រឹមតែមានសារៈសំខាន់ សម្រាប់ការការពារសិទ្ធិរបស់បុគ្គលនោះទេ ប៉ុន្តែថែមទាំងធានាថាសាធារណជនអាចទទួលបានព័ត៌មានត្រឹមត្រូវ ទាន់ពេលវេលា និងឯករាជ្យផងដែរ ។

ប្រសិនបើមិនមានកំណែទម្រង់ប្រកបដោយអត្ថន័យដើម្បីទប់ស្កាត់ការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌប្រឆាំងនឹងអ្នកសារព័ត៌មាន និងពិនិត្យមើលឡើងវិញនូវបទប្បញ្ញត្តិដែលមានលក្ខណៈរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជាពង្រឹងការការពារសម្រាប់អ្នកសារព័ត៌មានទេ នោះលំហសម្រាប់សារព័ត៌មានឯករាជ្យនៅកម្ពុជានឹងបន្តរួមតូចទៀត ។ ការធានាបាននូវបរិយាកាសសុវត្ថិភាព និងអំណោយផលសម្រាប់អ្នកសារព័ត៌មាន ជាកត្តាចាំបាច់សម្រាប់ការលើកកម្ពស់តម្លាភាព គណនេយ្យភាព ការចូលរួមរបស់សាធារណជនដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ និងអភិបាលកិច្ចបែបប្រជាធិបតេយ្យ។

៧. ឧបសម្ព័ន្ធ

១. អ្នកសារព័ត៌មានត្រូវបានសួរចម្លើយដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ព័ត៌មានលម្អិតនៃករណីនេះ មិនត្រូវបានបង្ហាញជាសាធារណៈនៅក្នុងរបាយការណ៍នេះទេដើម្បី ធានាថាវាមិនបង្កហានិភ័យបន្ថែមដល់អ្នកសារព័ត៌មាន ។
(ប្រភេទនៃសកម្មភាពៈ ការបំភិតបំភ័យ)

២. អ្នកសារព័ត៌មានម្នាក់ត្រូវបានគេគំរាមកំហែងនឹងប្រើហិង្សាលើរាងកាយ ខណៈពេលត្រឡប់មកពីយកព័ត៌មាន

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៦ អ្នកសារព័ត៌មានអនឡាញម្នាក់ ត្រូវបានរាយការណ៍ថាបានទទួលរងការគំរាមកំហែងដែលបង្កគ្រោះថ្នាក់ដល់រាងកាយពីជនមិនស្គាល់អត្តសញ្ញាណ ខណៈពេលត្រឡប់ពីបេសកកម្មយកព័ត៌មាននៅជិតច្រកព្រំដែនក្នុងខេត្តព្រះវិហារ ។

អ្នកសារព័ត៌មានរូបនេះបានប្រាប់ខេមបូចា នៅថ្ងៃទី៣ ខែកក្កដា ថាពេលលោកកំពុងចុះយកព័ត៌មានរឿងទាក់ទងនឹងការចោទប្រកាន់ថាមានការនាំចូលទំនិញថៃពីប្រទេសឡាវចូលមកកម្ពុជា តាមច្រកព្រំដែនមួយក្នុងខេត្តព្រះវិហារ ដោយៈកំពុងថតសកម្មភាពដឹកជញ្ជូនទំនិញតាមបណ្តោយខ្សែព្រំដែន លោកបានសង្កេតឃើញបុគ្គលម្នាក់ថតរូបលោក ដែលក្រោយមកបានជិះតាមពីក្រោយលោកនៅពេលលោកបើកឡានចេញពីទីនោះ ។
យោងតាមអ្នកសារព័ត៌មានរូបនេះ មានរថយន្តម៉ាក Toyota Highlander មួយគ្រឿង និងម៉ូតូមួយគ្រឿង បានជិះតាមលោក និងបានព្យាយាមបុករថយន្តរបស់លោកពីក្រោយជាច្រើនលើក ។

នៅពេលទៅដល់ភូមិណារ៉ុង ឃុំឆែបពីរ ស្រុកឆែប បុគ្គលម្នាក់បានចុះពីម៉ូតូ និងវាយលើរថយន្តរបស់លោក។ អ្នកសារព័ត៌មានបានបញ្ជាក់ថា មានបុគ្គលចំនួន ៤ នាក់ពាក់ព័ន្ធនឹងឧប្បត្តិហេតុនេះ ដែលក្នុងនោះ២នាក់ជិះក្នុងរថយន្ត និង ២ នាក់ទៀតជិះម៉ូតូ ។ ពួកគេទាំងអស់ពាក់ម៉ាស់ ដែលធ្វើឱ្យលោកមិនអាចកំណត់អត្តសញ្ញាណជនទាំងនោះបានឡើយ ។ ភ្លាមនោះលោកបានចាក់សោរទ្វាររថយន្ត និងបើកចាកចេញដោយសុវត្ថិភាព ។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៦ រដ្ឋបាលខេត្តព្រះវិហារ បានចេញសេចក្តីថ្លែងការណ៍មួយ ដោយអះអាងថាឧប្បត្តិហេតុនេះគឺជាជម្លោះផ្ទាល់ខ្លួនរវាងបុគ្គល និងបញ្ជាក់ថាអ្នកសារព័ត៌មានមិនបានដាក់ពាក្យបណ្តឹងជាផ្លូវការឡើយ ។ ទោះជាយ៉ាងណា អ្នកសារព័ត៌មានបានបដិសេធថាលោកមិនមានទំនាស់ផ្ទាល់ខ្លួនណាមួយជាមួយបុគ្គលទាំងនោះទេ ។

អ្នកសារព័ត៌មានដដែលបានឱ្យដឹងថា លោកបានរាយការណ៍ករណីនេះទៅនគរបាលតាមទូរស័ព្ទនៅថ្ងៃកើតហេតុ។ នៅថ្ងៃទី២៣ ខែមិថុនា នគរបាលខេត្តព្រះវិហារបានកោះហៅលោកទៅ ស្នងការដ្ឋាននគរបាលខេត្តដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យពីរនាក់ ដែលត្រូវបានចាប់ខ្លួនក្រោយការរាយការណ៍របស់លោក ។
ទោះជាយ៉ាងណានៅពេលទៅដល់ស្នងការនគរបាលមន្ត្រីនគរបាលបែរជាប្រាប់លោកថាលោកត្រូវបានប្តឹងដោយបុគ្គលឈ្មោះ លឹម ឆារី ទៅវិញដោយបានចោទប្រកាន់លោកពីបទរំលោភចូលកម្មសិទ្ធិឯកជន ។ អ្នកសារព័ត៌មានបានបញ្ជាក់ថាលោកមិនស្គាល់បុគ្គលនោះទេហើយក៏មិនយល់ពីមូលហេតុនៃការចោទប្រកាន់នេះដែរដោយអះអាងថា លោកគ្រាន់តែបានចូលទៅកាន់តំបន់ជិតព្រំដែនក្នុងគោលបំណងយកព័ត៌មានប៉ុណ្ណោះ ។

តាមការលើកឡើងរបស់អ្នកសារព័ត៌មានរូបនេះ នគរបាលបានប្រាប់លោកនៅពេលក្រោយថា សំណុំរឿងរំលោភចូលកម្មសិទ្ធិឯកជននេះ ត្រូវបានបញ្ជូនទៅតុលាការហើយ ។ អ្នកនាំពាក្យស្នងការដ្ឋាននគរបាលខេត្តព្រះវិហារបានបដិសេធមិនផ្តល់ព័ត៌មានបន្ថែមអំពីសំណុំរឿងនេះឡើយ ។
(ប្រភេទនៃសកម្មភាពៈ ការគំរាមកំហែងដល់សុវត្ថិភាពរាងកាយ)

៣. អ្នកសារព័ត៌មាន និងអ្នកសង្កេតការណ៍ ត្រូវបានហាមឃាត់មិនឱ្យចូលស្តាប់សវនាការនៅតុលាការកំពូល

នៅថ្ងៃទី១៩ ខែមិថុនា អ្នកសារព័ត៌មានម្នាក់ និងអ្នកសង្កេតការណ៍ម្នាក់មកពីសមាគមប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានបដិសេធមិនឱ្យចូលស្តាប់សវនាការនៅតុលាការកំពូល ៣ក់ព័ន្ធនឹងសំណុំរឿងអ្នកសារព័ត៌មានពីរនាក់ដែលត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ១៤ឆ្នាំ។ សវនាការនេះបានធ្វើឡើងចំថ្ងៃជាមួយគ្នានឹងសំណុំរឿងលោក រ៉ុង ឈុន ដែលមានអ្នកគាំទ្ររបស់លោករាប់រយនាក់ប្រមូលផ្តុំគ្នានៅខាងក្រៅតុលាការ។ អាជ្ញាធរបានដាក់របាំងការពារជុំវិញបរិវេណតុលាការ និងរឹតបន្តឹងការចូលទៅកាន់ទីតាំងនោះ។

តំណាងខេមបូចាដែលកំពុងឃ្លាំមើលសំណុំរឿងអ្នកសារព័ត៌មានទាំងពីររូបនាពេលនោះ បានស្នើសុំជាច្រើនលើកទៅកាន់អាជ្ញាធរ ដើម្បីអនុញ្ញាតឱ្យខ្លួនបានចូលស្តាប់សវនាការ ដោយពន្យល់អាជ្ញាធរថាគោលបំណងគឺគ្រាន់តែដើម្បីឃ្លាំមើលសំណុំរឿងអ្នកសារព័ត៌មានប៉ុណ្ណោះ ហើយមិនពាក់ព័ន្ធនឹងសំណុំរឿងលោក រ៉ុង ឈុន ទេ។ ទោះជាយ៉ាងណា សំណើនេះនៅតែត្រូវបានបដិសេធ ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦ តុលាការកំពូល បានបើកសវនាការលើសំណុំរឿងរបស់អ្នកសារព័ត៌មាន ជន សុភាព និង ភាព ភារ៉ា ដែលត្រូវបានតុលាការជាន់ទាបផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ១៤ ឆ្នាំ។
(ប្រភេទនៃសកម្មភាពៈ មិនអនុញ្ញាតឱ្យចូល)

៤. អ្នកសារព័ត៌មានពីរនាក់ ត្រូវបានរារាំងមិនឱ្យថតរូបពីការតវ៉ានៅមុខស្ថានទូតចិន

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦ អ្នកថតរូបម្នាក់ និងពលរដ្ឋអ្នកសារព័ត៌មានជាស្ត្រីម្នាក់ ត្រូវបានមន្ត្រីនគរបាលរារាំងមិនឱ្យថតរូបក្រុមអ្នកតវ៉ានៅមុខស្ថានទូតចិនក្នុងរាជធានីភ្នំពេញ។

ឧប្បត្តិហេតុនេះបានកើតឡើង ខណៈដែលក្រុមអ្នកតវ៉ារួមមានទាំងជនជាតិចិនដែរ ដែលអះអាងថាជាជនរងគ្រោះដោយធនាគារ Huione បានប្រមូលផ្តុំគ្នានៅមុខស្ថានទូតចិន ដើម្បីស្វែងរកអន្តរាគមន៍ឱ្យបានទទួលប្រាក់ដែលពួកគេអះអាងថាបាត់បង់ដោយសារធនាគារនេះត្រឡប់មកវិញ។

អ្នកថតរូបបានប្រាប់ថា ខណៈពេលលោកកំពុងថតរូបព្រឹត្តិការណ៍នោះ មន្ត្រីនគរបាលដើរមករកគាត់ ហើយបានសួរគាត់ថា៖ «តើអ្នកមានការអនុញ្ញាតពីស្ថានទូតហើយឬនៅ?»។ ទោះបីជាគាត់ឈរនៅទីសាធារណៈខាងក្រៅបរិវេណស្ថានទូតក៏ដោយ នគរបាលបានបញ្ជាឱ្យលុបរូបថតទាំងអស់ដែលពាក់ព័ន្ធនឹងស្ថានទូតចិន។ អ្នកថតរូបបានអនុវត្តតាម ដើម្បីជៀសវាងការឃាត់ខ្លួន។

ក្នុងហេតុការណ៍ដដែលនេះ ពលរដ្ឋអ្នកសារព័ត៌មានជាស្ត្រីម្នាក់ ក៏ត្រូវបានរារាំងមិនឱ្យថតរូបផងដែរ។ អ្នកសារព័ត៌មានរូបនោះ បានប្រាប់ខេមបូចាថា ខណៈដែលកំពុងថតរូបការតវ៉ានោះ មន្ត្រីនគរបាលបានដើរមករកគាត់ ហើយបានដកយកទូរស័ព្ទរបស់គាត់ និងលុបរូបថតទាំងអស់ដែលគាត់បានថត។ វីដេអូមួយដែលខេមបូចាបានឃើញ បង្ហាញថាខណៈពលរដ្ឋអ្នកសារព័ត៌មាន រូបនេះកំពុងថតសកម្មភាពនៃការតវ៉ា មន្ត្រីនគរបាលម្នាក់ដើរចូលមក និងដកយកទូរស័ព្ទស្មាតហ្វូនរបស់គាត់ ។

អ្នកសារព័ត៌មានទាំងពីរបានបញ្ជាក់ថា ក្រោយមកពួកគេត្រូវបានអនុញ្ញាតឱ្យបន្តស្ថិតនៅក្នុងបរិវេណនោះ ប៉ុន្តែត្រូវបានព្រមានមិនឱ្យថតរូបបន្តទៀតទេ ។
(ប្រភេទនៃសកម្មភាព៖ ការរារាំង ឬលុបខ្លឹមសារ)

៥. អ្នកថតរូបសារព័ត៌ម្នាក់ត្រូវបានឃាត់ខ្លួនដើម្បីសួរចម្លើយ ខណៈពេលកំពុងរាយការណ៍ពីការតវ៉ានៅមុខស្ថានទូតចិន

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦ អ្នកថតរូបម្នាក់មកពីស្ថាប័នប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ត្រូវបានឃាត់ខ្លួន និងបញ្ជូនទៅប៉ុស្តិ៍នគរបាលរដ្ឋបាលទួលស្វាយព្រៃ១ ដើម្បីសួរចម្លើយ ខណៈពេលកំពុងរាយការណ៍ពីការតវ៉ារបស់អតិថិជនធនាគារ Huione នៅមុខស្ថានទូតចិន ក្នុងរាជធានីភ្នំពេញ ។ តាមព័ត៌មាននាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦ ដែលខេមបូចាទទួលបានពីនិពន្ធនាយកសារព័ត៌មានរបស់ស្ថាប័ននោះ អ្នកសារព័ត៌មានរូបនេះត្រូវបានឃាត់ ខ្លួនប្រមាណ២ម៉ោងនៅប៉ុស្តិ៍នគរបាល មុនពេលត្រូវបានដោះលែងវិញបន្ទាប់ពីមានការអន្តរាគមន៍ពីនិពន្ធនាយក របស់ខ្លួន។ និពន្ធនាយក រូបនោះបានពន្យល់ប្រាប់នគរបាលថា អ្នកថតរូបរបស់ខ្លួនកំពុងបំពេញតួនាទីវិជ្ជាជីវៈរបស់គេប៉ុណ្ណោះ ។ ទាំងអ្នកសារព័ត៌មាន និងនិពន្ធនាយក បានបដិសេធមិនផ្តល់ព័ត៌មានលម្អិតបន្ថែមជុំវិញករណីនេះទៀតឡើយ ។
(ប្រភេទនៃសកម្មភាព៖ ការឃុំខ្លួន)

៦. អ្នកសារព័ត៌មានបរទេសដែលរាយការណ៍នៅកម្ពុជា ត្រូវបានគំរាមកំហែង

អ្នកសារព័ត៌មានបរទេសម្នាក់ ដែលត្រូវបានគេស្គាល់ថាតែងតែរាយការណ៍អំពីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការឆបោក និងករណីចាប់ជំរិត នៅកម្ពុជា បានអះអាងថាលោកត្រូវបានគំរាមកំហែងដោយម្ចាស់អាជាតមិនមួយ នៅរាជធានីភ្នំពេញ ជាទីតាំងត្រូវបានចោទប្រកាន់ថាជាកន្លែងកើតហេតុនៃករណីចាប់ជំរិត់មួយ។

អ្នកសារព័ត៌មានរូបនេះបានប្រាប់ខេមបូចា នៅថ្ងៃទី២ ខែមិថុនា ថា ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៦ ។ លោកបានអះអាងថា គូស្វាមីភរិយាជនបរទេស ដែលជាម្ចាស់អាជាតមិន បានផ្ញើសារគំរាមកំហែងមកលោកតាមរយៈ WeChat បន្ទាប់ពីលោកបានផ្សាយអត្ថបទពីករណីចាប់ជំរិតមួយដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅទីតាំងនោះ ។ យោងតាមអ្នកសារព័ត៌មានដដែល គូស្វាមីភរិយាខាងលើបានទាមទារឱ្យលោកលុបឈ្មោះអាជាតមិនចេញពីអត្ថបទ និងបានព្រមានថាលោកនឹងទទួលរងផលវិបាកប្រសិនបើមិនអនុវត្តតាម ។

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៦ អ្នកសារព័ត៌មានរូបនេះក៏បានសរសេរនៅលើគណនី X របស់លោកថា៖ «មិនមានពេលទៀតទេ វាពិតជាលំបាកក្នុងការធ្វើសេចក្តីរាយការណ៍ ជាភាសាចិននៅកម្ពុជា ។ ម្សិលមិញ យើងបានទទួលការគំរាមកំហែងមួយទៀត ដោយសារតែការរាយការណ៍អំពីករណីចាប់ជំរិតនៅ [អាជាតមិនមួយ] ។ ពួកគេថែមទាំងទាមទារឱ្យ Tencent បិទគណនី WeChat ផ្លូវការរបស់យើងទៀតផង» ។

អ្នកសារព័ត៌មានបានបញ្ជាក់ថាគូស្វាមីភរិយានោះក៏បានផ្តល់ប្រាក់ឱ្យលោកជាថ្នូរនឹងការលុបអត្ថបទផងដែរ ប៉ុន្តែលោកបានបដិសេធ ។ លោកថាស្ត្រីជាភរិយាម្ចាស់អគារនោះបានបន្តព្រមានលោក ដោយនិយាយថា៖ «កុំធ្វើឱ្យមនុស្សកាន់តែច្រើនរងគ្រោះ» ។

ទោះជាយ៉ាងណា លោកបានបញ្ជាក់ថា ស្ថានការណ៍បានធូរស្រាលឡើងវិញ បន្ទាប់ពីគូស្វាមីភរិយានោះបានដកពាក្យបណ្តឹងរបស់ពួកគេចេញពី WeChat នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៦។ អ្នកសារព័ត៌មានមិនបានបញ្ជាក់ពីមូលហេតុនៃការដកពាក្យបណ្តឹងឡើយ ។ នៅពេលដែលសួរថាតើអត្ថបទព័ត៌មានរបស់លោកពាក់ព័ន្ធនឹងការចាប់ជំរិតនោះត្រូវបានដកចេញហើយមែនទេ លោកបានបញ្ជាក់ថា អត្ថបទនោះនៅតែមានផ្សាយនៅលើអនឡាញដដែល និងមិនត្រូវបានលុបចេញឡើយ។
(ប្រភេទនៃសកម្មភាព៖ ការគំរាមកំហែង)

៧. អ្នកសារព័ត៌មានម្នាក់រងការវាយប្រហារ ខណៈពេលថតរូបរថយន្តដឹកឈើ

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ អ្នកសារព័ត៌មានម្នាក់មកពី NMR TV ប្រចាំខេត្តរតនគិរី បានរងនូវការវាយប្រហារដោយបុរសម្នាក់ដែលត្រូវបានគេស្គាល់ថាជាអ្នកបើកបររថយន្តដឹកឈើនៅក្នុងខេត្តរតនគិរី ។ អ្នកសារព័ត៌មានរូបនេះត្រូវបានចាប់បោក និងផ្តួលទៅលើដីក្នុងអំឡុងពេលនៃហេតុការណ៍នោះ : ។

អ្នកសារព័ត៌មានរូបនោះបានប្រាប់ខេមបូចាថានៅថ្ងៃកើតហេតុលោក និងអ្នកសារព័ត៌មានពីរនាក់ទៀតបានជិះម៉ូតូធ្វើដំណើរ។ នៅតាមផ្លូវ ពួកគេបានឃើញរថយន្តដឹកឈើមួយគ្រឿងចតនៅមុខផ្ទះបុរសម្នាក់ ដែលក្រោយមកបានក្លាយជាជនបង្ក ។

អ្នកសារព័ត៌មានបានបន្តថា ពួកគេបានឈប់នៅខាងក្រោយរថយន្តនោះ ហើយព្យាយាមថតរូប ។ នៅពេលនោះ បុរសម្នាក់បានដើរសំដៅមកពួកគេ និងសួរថា៖ «អ្នកកំពុងធ្វើអីនៅខាងក្រោយឡានហ្នឹង?»។ ជាការឆ្លើយតប អ្នកសារព័ត៌មានម្នាក់បានសួរបកវិញថាតើរថយន្តហ្នឹងដឹកអ្វីដែរ ។

បុរសនោះបានឆ្លើយថារថយន្តកំពុងដឹកឈើឱ្យ «មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលម្នាក់»។ បន្ទាប់មកគាត់បាននិយាយក្នុងន័យចំអកថា៖«ចង់ថតរូបមែនទេ? អីចឹងថតទៅ!»។

អ្នកសារព័ត៌មានបានបញ្ជាក់ថាលោកបានបន្តថតរូបរថយន្តដែលបណ្តាលឱ្យមានការឈ្លោះប្រកែកគ្នា។ស្ថានការណ៍បានឈានដល់ការប្រើអំពើហិង្សាដោយជនបង្កបានចាប់បោកលោកផ្តួលទៅលើដី។

អ្នកសារព័ត៌មានផ្សេងទៀតដែលនៅកន្លែងកើតហេតុ បានចូលអន្តរាគមន៍ និងជួយជនរងគ្រោះចាកចេញពីទីតាំង។ ហេតុការណ៍នេះបានកើតឡើងនៅភូមិ២ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរី។

អ្នកសារព័ត៌មានរូបនេះបានឱ្យដឹងថា ជនដែល បង្កហេតុត្រូវបានប្រជាការពារភូមិឃាត់ខ្លួនភ្លាមៗ និងប្រគល់ទៅឱ្យនគរបាលឃុំ បន្ទាប់ពីមានការដាក់ពាក្យបណ្តឹង ។

យោងតាមព័ត៌មានដែលអ្នកសារព័ត៌មានទទួលបាននៅពេលក្រោយ ជនសង្ស័យត្រូវបានដោះលែង នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៦ ដោយព្រះរាជអាជ្ញានៃសាលាដំបូងខេត្តរតនគិរី ។ ទោះជាយ៉ាងណា អ្នកសារព័ត៌មានបានបញ្ជាក់ថា លោកមិនត្រូវបានជូនដំណឹងអំពីមូលហេតុនៃការដោះលែងនោះទេ។

នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦ អ្នកសារព័ត៌មាន និងមេធាវីរបស់លោកត្រូវបានសាលាដំបូងខេត្ត កោះហៅឱ្យចូលបំភ្លឺពាក់ព័ន្ធនឹងឧប្បត្តិហេតុនេះ។ លោកបានឱ្យដឹងថា ក្នុងអំឡុងពេលសួរចម្លើយ មន្ត្រីតុលាការម្នាក់បានសួរនាំលោកអំពីសំណុំរឿងនេះ ប៉ុន្តែបានបញ្ជាក់ថា នឹងមិនមានចំណាត់ការ បន្ថែមទៀតឡើយ ដោយសារជនដែលត្រូវបានចោទប្រកាន់ថាជាជនបង្កហេតុត្រូវបានដោះ លែងរួចហើយ។
(ប្រភេទនៃសកម្មភាព៖ ហិង្សាលើរាងកាយ)

៨. អ្នកសារព័ត៌មានម្នាក់ត្រូវបានឃុំខ្លួន ពាក់ព័ន្ធនឹងសេចក្តីរាយការណ៍ពីមន្ទីរពេទ្យមួយនៅភ្នំពេញ

ព័ត៌មានលម្អិតនៃករណីនេះ មិនត្រូវបានបង្ហាញជាសាធារណៈនៅក្នុងរបាយការណ៍នេះទេដើម្បី ធានាថារាមិនបង្ហានិ ភ័យបន្ថែមដល់អ្នកសារព័ត៌មាន ។

៩. អ្នកសារព័ត៌មានត្រូវបានកោះហៅ បន្ទាប់ពីរាយការណ៍ពីការឃាត់ខ្លួនជនជាតិចិន

នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ អ្នកសារព័ត៌មានម្នាក់មកពីសារព័ត៌មាន កោះកុងហតញ (Koh Kong Hot News) ត្រូវបាននគរបាលខេត្តកោះកុង កោះហៅមកសាកសួរអស់រយៈពេល ៧ ម៉ោង បន្ទាប់ពីលោកបានរាយការណ៍ពីការឃាត់ខ្លួនជនជាតិចិនមួយក្រុម ក្នុងអំឡុងពេលប្រតិបត្តិការបង្ក្រាបជនអន្តោប្រវេសន៍ខុសច្បាប់នៅក្នុងខេត្ត ។

ការកោះហៅនេះបានធ្វើឡើង បន្ទាប់ពីអ្នកសារព័ត៌មានរូបនេះបានផ្សាយសេចក្តីរាយការណ៍មួយ ដែលថានគរបាលខេត្តកោះកុង បានឃាត់ខ្លួនជនជាតិចិនមួយក្រុមនៅក្នុងខេត្តដោយបំពាននីតិវិធី។

ក្នុងបទសម្ភាសន៍ជាមួយខេមបូចានាថ្ងៃទី២ ខែមេសា អ្នកសារព័ត៌មានដដែលបានបញ្ជាក់ថាបញ្ហានេះត្រូវបានបញ្ចប់ហើយបន្ទាប់ពីលោកយល់ព្រមលុបព័ត៌មាននោះតាមសំណើនគរបាលខេត្ត ។ ពុំមានការចោទប្រកាន់ជាផ្លូវការណាមួយ ត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងការកោះហៅនេះឡើយ ។

កាលពីថ្ងៃទី៣១ ខែមីនាកន្លងទៅ អ្នកសារព័ត៌មានរូបនេះក៏ត្រូវបាននគរបាលខេត្តពោធិ៍សាត់ កោះហៅឱ្យចូលបំភ្លឺផងដែរ បន្ទាប់ពីលោកបានរាយការណ៍អំពីប្រតិបត្តិការបង្ក្រាបដូចគ្នានេះដែរ ខេត្តពោធិ៍សាត់។ អាជ្ញាធរបានចោទប្រកាន់លោកពីបទប្រមាថជាសាធារណៈពាក់ព័ន្ធនឹងសេចក្តីរាយការណ៍នោះ ដែលក្រោយមកក៏ត្រូវបានដកចេញផងដែរតាមការបញ្ជារបស់អាជ្ញាធរមូលដ្ឋាន។
(ប្រភេទនៃសកម្មភាព៖ ការកោះហៅ/សួរចម្លើយ)

១០. អ្នកសារព័ត៌មានម្នាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងការបោះសារនៅលើបណ្តាញហ្វេសប៊ុក

នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦ អ្នកសារព័ត៌មានម្នាក់មកពីសារព័ត៌មាន PKN Hot News ត្រូវបាននគរបាលខេត្តកំពង់ស្ពឺ ចាប់ខ្លួនដោយសហការជាមួយនគរបាលស្រុកត្រាំកក់ ខេត្តតាកែវ ។ លោកត្រូវបានបញ្ជូនទៅតុលាការដើម្បីសួរចម្លើយពាក់ព័ន្ធនឹងការបង្ហោះសារនៅលើ ហ្វេសប៊ុកដែលបានរិះគន់មន្ត្រីតុលាការខេត្តម្នាក់ ជុំវិញការចោទប្រកាន់ថាបានទទួលសំណូកពីអ្នកលេងល្បែង ។

យោងតាមអង្គការសិទ្ធិមនុស្សអាដហុកអ្នកសារព័ត៌មានរូបនេះត្រូវបានចាប់ខ្លួនដោយគ្មានការបញ្ជាក់មូលហេតុច្បាស់លាស់។ ព័ត៌មានដែលប្រមូលបានពីការបង្ហោះនៅលើបណ្តាញសង្គម បង្ហាញថា ការចាប់ខ្លួននេះអាចមានទំនាក់ទំនងនឹងសំណេរដែលលោកបានបង្ហោះកាលពីពាក់កណ្តាលខែមីនា ឆ្នាំ២០២៦។ ក្នុងការបង្ហោះនោះ លោកបានចោទថា មន្ត្រីតុលាការខេត្តកំពង់ស្ពឺម្នាក់ បានទទួលសំណូកពីអ្នកលេងល្បែងជល់មាន់ម្នាក់ចំនួន ២០០០ ដុល្លារអាមេរិក ដែលសរុបទាំងអស់ ៦០០០ដុល្លារ ដើម្បីជាថ្នូរក្នុងការដោះលែងពួកគេ ។ លោកក៏បានអះអាងផងដែរថា អាជ្ញាធរខេត្តជាអ្នកនៅពីក្រោយល្បែងស៊ីសងខុសច្បាប់ទាំងនេះ ។

របាយការណ៍ឃ្លាំមើលប្រចាំត្រីមាស

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ បានចេញលិខិតមួយបដិសេធខ្លឹមសារនៃព័ត៌មាននោះ។ លិខិតនោះបានបញ្ជាក់ថា មនុស្ស ៣ នាក់ ត្រូវបានចោទប្រកាន់ពីបទបើកល្បែងអនឡាញ។ ទោះជាយ៉ាងណាបន្ទាប់ពីការចាប់ខ្លួន និងសួរចម្លើយ តុលាការបានរកឃើញថាករណីនេះពាក់ព័ន្ធត្រឹមតែបទមជ្ឈិមប៉ុណ្ណោះ ។ លិខិតនោះក៏បានបញ្ជាក់ផងដែរថា អ្នកសារព័ត៌មានគួរតែធ្វើការផ្ទៀងផ្ទាត់ព័ត៌មានឱ្យបានហ្មត់ចត់ជាងនេះ មុននឹងផ្សព្វផ្សាយ។ ប៉ុន្មានថ្ងៃក្រោយមក គឺនៅថ្ងៃទី២ ខែមេសា អ្នកសារព័ត៌មានរូបនេះត្រូវបានចាប់ខ្លួន។

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៦ ទំព័រហ្វេសប៊ុក PKN Hot News បានបង្ហោះវីដេអូមួយ ដែលក្នុងនោះអ្នកសារព័ត៌មានបានសុំទោសនិងទទួលស្គាល់កំហុស បន្ទាប់ពីត្រូវបានដោះលែង ។ ខេមបូចា បានព្យាយាមទាក់ទងអ្នកសារព័ត៌មានរូបនោះ និងក្រុមគ្រួសាររបស់លោកជាច្រើនលើក ដើម្បីស្នើសុំព័ត៌មានបន្ថែម ប៉ុន្តែមិនអាចទាក់ទងបានឡើយ។ អង្គការសិទ្ធិមនុស្សក្នុងស្រុកមួយទៀត គឺលីកាដូ ក៏បានបញ្ជាក់អំពីករណីនេះផងដែរ បើទោះបីជាមិនមានព័ត៌មានលម្អិតបន្ថែមក៏ដោយ។
(ប្រភេទនៃសកម្មភាព៖ ការឃុំខ្លួន)។

រាយការណ៍អំពីករណីរំលោភសិទ្ធិមនុស្សលើអ្នកសារព័ត៌មាន ៖

+៨៥៥ ១០ ៨៨២ ៣១១ (តេឡេក្រាម)

feedback@camboja.net

អេសអេសភី អូហ្វីស ស្ពេស ជាន់ទី៤(G) ផ្ទះលេខ៤៨
មហាវិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

www.camboja.net